JS LAND PLC

លេខ ២០២២/EGMMINUTES/០១

**កំណត់ហេតុ**

**ស្តីពី**

**សន្និបាតវិសាមញ្ញលើកទីមួយរបស់ក្រុមហ៊ុន JS LAND PLC.**

ក្រុមហ៊ុន JS LAND PLC. (CSX៖ JSL) សូមជម្រាបជូនម្ចាស់ភាគហ៊ុនគ្រប់រូបឲ្យបានជ្រាបថា សន្និបាតវិសាមញ្ញ (EGM) ត្រូវបានប្រារព្ធធ្វើឡើងតាមបែបនិម្មិត ចាប់ពីម៉ោងប្រហែល ០៩:៣០ នាទីព្រឹក រហូតដល់ ម៉ោង ១០:៣០ ព្រឹក នៅថ្ងៃអង្គារ ទី០៦ ខែតុលា ឆ្នាំ២០២២។ ដោយមានសំណើ ដែលត្រូវអនុម័តដោយម្ចាស់ភាគហ៊ុនដូចខាងក្រោម៖

ប្រធានបទទី១ - ការបោះឆ្នោត និងការតែងតាំងក្រុមប្រឹក្សាភិបាលចំនួន ៣ រូបបន្ថែមទៀត និង អភិបាលឯករាជ្យចំនួន ១ រូប។
ប្រធានបទទី២ - ការអនុម័តសេចក្តីសម្រេចស្តីពីការកែសម្រួលអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន ("M&A")។

មុនពេលរៀបចំសន្និបាតនៅថ្ងៃនេះ JS Land បានបង្កើតកំណត់ត្រា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ ដូច្នេះម្ចាស់ភាគហ៊ុន ដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះម្ចាស់ភាគហ៊ុន ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២២ (កាលបរិច្ឆេទធ្វើកំណត់ត្រា) បានទទួលលិខិតអញ្ជើញតាមរយៈអ៊ីមែល និងតេឡេក្រាម ពី ធនាគារ អេស៊ីលីដា ភីអិលស៊ី (ភ្នាក់ងារផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ប្រាក់របស់ JSL) ចាប់ពីថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២។ (មានភ្ជាប់មកជាមួយនូវលិខិត របស់ម្ចាស់ភាគហ៊ុនដែលបានចុះបញ្ជី)

EGM បានទទួលម្ចាស់ភាគហ៊ុនចំនួន ១០ រូប ដែលមានសមតុល្យភាគហ៊ុនសរុបចំនួន ២៣.១៥៨.៧៥៩ ស្របតាមកូរ៉ុមចំនួន ៥១% នៃម្ចាស់ភាគហ៊ុន ដែលចាំបាច់សម្រាប់ការបោះឆ្នោត និងការតែងតាំង សមាជិកក្រុមប្រឹក្សាភិបាល និងសេចក្តីសម្រេចរបស់ក្រុមហ៊ុនក្នុងការពង្រីកក្រុមប្រឹក្សាភិបាល។

ម្ចាស់ភាគហ៊ុនដែលបានចុះបញ្ជី បានចូលរួម EGM

JS LAND PLC

| ល.រ. | អត្តលេខវិនិយោគិន | ឈ្មោះម្ចាស់ភាគហ៊ុន | ភាគហ៊ុន |
|---|---|---|---|
| ១ | D៦៦៧៨៧៨០១៣៤៥ | KOY LE SAN | ៦.៤៧១.៦០០ |
| ២ | F១១២៦៣៣០៧១៩៦ | YAP TING CHIAT | ៦.៤៧១.៦០០ |
| ៣ | F៥០៤៧៨៧៧៧៥៥១ | NORDEST ASIA CAPITAL CO., LTD. | ២.៥៧១.០០០ |
| ៤ | D៣៤៨០១៧៥០៦១៨ | MENG LEE | ១.៧៤២.៩០០ |
| ៥ | D៨៣២២៣៣៧៤៨៤៨ | KIN SOLYTA | ១.៧៤២.៩០០ |
| ៦ | F២៩៤៦៩៥៣០២៦១ | PHRONTIER CAPITAL CO., LTD. | ១.២៨៥.៥០០ |
| ៧ | F៣៨៩៦០៦៣៧៥៤៦ | CT DEVELOPMENT PPC LIMITED | ១.២៨៥.៥០០ |
| ៨ | F៧៥២១១៧២៧៥៦៧ | TANG CHUN KIU | ១.០០០.០០០ |
| ៩ | F៩២៦៣៧៦២៦៨៤៨ | YAP MAOW JUN | ៤៩៤.៤៥៧ |
| ១០ | F១៤៥២០២១៨៦៦៨ | YAP TENG WUI | ៨៣.២៩២ |
| | | **ភាគហ៊ុនដែលបានចុះបញ្ជីសរុប** | **២៣.១៤៨.៧៤៩** |
| | | ភាគហ៊ុនដែល JS LAND បានចេញសរុប | ២៥.៧១០.០០០ |
| | | ភាគរយ | ៩០.០៣៧៩១៩១ |

<u>ប្រធានបទទី១ - ការបោះឆ្នោត និងការតែងតាំងក្រុមប្រឹក្សាភិបាលចំនួន ៣ រូបបន្ថែមទៀត និងក្រុមប្រឹក្សាភិបាលឯករាជ្យចំនួន ១ រូប</u>

Dato' Jack Yap ជានាយកប្រតិបត្តិ និងប្រធាននាយកប្រតិបត្តិ បានស្នើសុំតែងតាំងក្រុមប្រឹក្សាភិបាលចំនួន ៣ រូបបន្ថែមទៀត និងអភិបាលឯករាជ្យចំនួន ១ រូប នៅក្នុងក្រុមប្រឹក្សាភិបាល ដូចខាងក្រោម៖

១. Yap Maow Jun (ក្រុមប្រឹក្សាភិបាល)
២. Yap Teng Wui (ក្រុមប្រឹក្សាភិបាល)
៣. Tang Chat Tong (ក្រុមប្រឹក្សាភិបាល)
៤. Dato Tan Teck Zin (ក្រុមប្រឹក្សាភិបាលឯករាជ្យ)

សំណើនេះត្រូវបានគាំទ្រដោយ ឧកញ៉ា KOY LE SAN នាយកប្រតិបត្តិនៃក្រុមហ៊ុន JS Land Plc.។

ការបោះឆ្នោតសម្រាប់ក្រុមប្រឹក្សាភិបាលទាំង ៣ រូប និងក្រុមប្រឹក្សាភិបាលឯករាជ្យចំនួន ១ រូប ត្រូវបានធ្វើឡើង។

ក្នុងអំឡុងពេលបោះឆ្នោត ម្ចាស់ភាគហ៊ុនចំនួន ២ រូប (Meng Lee និង Tang Chun Kiu) មិនអាចទទួលបានទម្រង់នៃការបោះឆ្នោតនោះទេ។ ការបោះឆ្នោតរបស់ពួកគេត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ និងត្រូវបានថតទុក។

ការបោះឆ្នោតបានចំណាយពេលប្រហែល ១៥ នាទី។

ប្រធានបទទី២ - ការអនុម័តសេចក្តីសម្រេចស្តីពីការកែសម្រួលអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន ("M&A")

ប្រធានបទទី២ សម្រាប់ការអនុម័តសេចក្តីសម្រេចស្តីពីការកែសម្រួលអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន ត្រូវបានស្នើឡើងដោយ Dato' Jack Yap។

សំណើនេះត្រូវបានគាំទ្រដោយ Yap Ting Wui។

ក្នុងអំឡុងពេលបោះឆ្នោត ម្ចាស់ភាគហ៊ុនចំនួន ២ រូប (Meng Lee និង Tang Chun Kiu) មិនអាចទទួលបានទម្រង់នៃការបោះឆ្នោតនោះទេ។ ការបោះឆ្នោតរបស់ពួកគេត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ និងត្រូវបានថតទុក។

ការបោះឆ្នោតបានចំណាយពេលប្រហែល ៥ នាទី។

ការប្រកាសលទ្ធផលនៃការបោះឆ្នោត
ការធ្វើតារាងលទ្ធផលនៃការបោះឆ្នោតបានចំណាយពេលប្រហែល ១៥ នាទី។

JS LAND PLC

## លទ្ធផលរបស់ប្រធានបទទី១ - ការបោះឆ្នោត និងការតែងតាំងក្រុមប្រឹក្សាភិបាលចំនួន ៣ រូប បន្ថែមទៀត និងក្រុមប្រឹក្សាភិបាលឯករាជ្យចំនួន ១ រូប

ម្ចាស់ភាគហ៊ុនភាគច្រើនបានបោះឆ្នោតជូនក្រុមប្រឹក្សាភិបាលទាំងបីរូបបន្ថែមទៀត និងក្រុមប្រឹក្សាភិបាលឯករាជ្យមួយរូបបន្ថែមទៀតនោះ។ លទ្ធផលនៃសន្និបាតវិសាមញ្ញរបស់ម្ចាស់ភាគហ៊ុន រួមជាមួយសំឡេងឆ្នោតរបស់ពួកគេត្រូវបានរៀបរាប់នៅខាងក្រោម៖

| ល.រ. | កម្មវត្ថុ | ចំនួនភាគហ៊ុន (គាំទ្រ) | ភាគរយ (គាំទ្រ) | ចំនួនភាគហ៊ុន (ប្រឆាំង) | ភាគរយ (ប្រឆាំង) |
|---|---|---|---|---|---|
| ក | ការបោះឆ្នោត និងការតែងតាំង Yap Maow Jun ជាក្រុមប្រឹក្សាភិបាល | ២៣.១៤៨.៧៤៩,០០ | ១០០% | 0 | 0 |
| ខ | ការបោះឆ្នោត និងការតែងតាំង Yap Ting Wui ជាក្រុមប្រឹក្សាភិបាល | ២៣.១៤៨.៧៤៩,០០ | ១០០% | 0 | 0 |
| គ | ការបោះឆ្នោត និងការតែងតាំង Tang Chat Tong ជាក្រុមប្រឹក្សាភិបាល | ២៣.១៤៨.៧៤៩,០០ | ១០០% | 0 | 0 |
| ឃ | ការបោះឆ្នោត និងការតែងតាំង Dato' Tan Teck Zin ជាក្រុមប្រឹក្សាភិបាលឯករាជ្យ | ២៣.១៤៨.៧៤៩,០០ | ១០០% | 0 | 0 |

(របាយការណ៍នៃការបោះឆ្នោតតាមប្រព័ន្ធឌីជីថល និងសន្និបាតតាមបែបនិម្មិតត្រូវបានថតទុក)

ដូច្នេះ សេចក្តីសម្រេចត្រូវបានធ្វើឡើង។

## លទ្ធផលរបស់ប្រធានបទទី២ - ការអនុម័តសេចក្តីសម្រេចស្តីពីការកែសម្រួលអនុស្សរណៈ និង លក្ខន្តិកៈក្រុមហ៊ុន ("M&A")

| ល.រ. | កម្មវត្ថុ | ចំនួនភាគហ៊ុន (គាំទ្រ) | ភាគរយ (គាំទ្រ) | ចំនួនភាគហ៊ុន (ប្រឆាំង) | ភាគរយ (ប្រឆាំង) |
|---|---|---|---|---|---|
| ក | ការអនុម័តសេចក្តីសម្រេចស្តីពីការកែសម្រួលអនុស្សរណៈ និង លក្ខន្តិកៈក្រុមហ៊ុន ("M&A") | ២៣.១៤៨.៧៤៩,០០ | ១០០% | 0 | 0 |

(របាយការណ៍នៃការបោះឆ្នោតតាមប្រព័ន្ធឌីជីថល និងសន្និបាតតាមបែបនិម្មិតត្រូវបានថតទុក)

ដូច្នេះ សេចក្តីសម្រេចត្រូវបានធ្វើឡើង។

ភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

ក្រុមហ៊ុន JS LAND PLC.

JS LAND PLC
KINGDOM OF CAMBODIA